អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**ផ្នែកកិច្ចការសាធារណៈ**

ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១៦

# សេចក្តីប្រកាសព័ត៌មាន
# សហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេច
# បំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤

សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបំបែកសំណុំរឿងជនត្រូវចោទ អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ ហើយចាត់ជាសំណុំរឿងថ្មីមួយ គឺសំណុំរឿង ០០៤/០១។

ការបំបែកសំណុំរឿងនេះ គឺដើម្បីធានាសិទ្ធិរបស់ជនត្រូវចោទចំពោះការកំណត់បទចោទប្រឆាំងនឹងរូបគាត់ដោយគ្មានការពន្យារពេល។ ដោយពិចារណាដល់សេចក្តីជូនដំណឹងពីការបិទបញ្ចប់កិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ដែលបានចេញកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១៥ ខណៈដែលការស៊ើបអង្កេតប្រឆាំងនឹងជនត្រូវចោទផ្សេងទៀត ក្នុងសំណុំរឿង ០០៤ កំពុងតែនៅបន្តនៅឡើយ សហចៅក្រមស៊ើបអង្កេត យល់ឃើញថា វាជាការត្រឹមត្រូវ និងដើម្បីផលប្រយោជន៍យុត្តិធម៌គឺត្រូវបំបែកជនត្រូវចោទអ៊ឹម ចែម ចេញពីសំណុំរឿង០០៤។ ការណ៍នេះនឹងអនុញ្ញាតឱ្យនីតិវិធីប្រឆាំងនឹង អ៊ឹម ចែម ឈានដល់ការបិទបញ្ចប់ ខណៈដែលការស៊ើបអង្កេតនៅតែបន្តចំពោះផ្នែកដែលនៅសេសសល់ ក្នុងសំណុំរឿង ០០៤។

លោកអ្នកអាចរកបានដីកាសម្រេចបំបែកសំណុំរឿងនេះនៅលើគេហទំព័ររបស់ អ.វ.ត.ក
http://www.eccc.gov.kh/document/court/36609

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិកៈ olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh